**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សេចក្តីអំពាវនាវដល់បណ្តាញព័ត៌មាន

ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសង្កេតឃើញថា បណ្តាញព័ត៌មានទាំងឡាយ មានទូរទស្សន៍ កាសែត វិទ្យុ បានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយ និង ដោយសេរីអំពីការរីករាលដាលមេរោគអេដស៍នៅខេត្តបាត់ដំបង ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមទទួលស្គាល់តួនាទីរបស់បណ្តាញព័ត៌មាន ក្នុងការផ្សព្វផ្សាយព័ត៌មានទាំងនោះ ដែលឆ្លុះបញ្ចាំងពីការលើកកម្ពស់សេរីភាពសារព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្សយ៉ាងពិតប្រាកដ ។

ជាមួយនោះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏សូមទាញការយកចិត្តទុកដាក់របស់អ្នកទទួលខុសត្រូវបណ្តាញព័ត៌មានទាំងអស់ ឱ្យចូលរួមរក្សាភាពសម្ងាត់របស់អ្នកផ្ទុកមេរោគអេដស៍ ។ ការរក្សាភាពសម្ងាត់នេះ ជាវិធីការពារមួយកុំឱ្យមានការរើសអើងនៅក្នុងសង្គម រីឯការរើសអើងក្រោមរូបភាពណាក៏ដោយជាការរំលោភសិទ្ធិមនុស្សមួយយ៉ាងធ្ងន់ធ្ងរ ។ ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ជាពិសេសដើម្បីកុំឱ្យមានការរើសអើងអ្នកផ្ទុកមេរោគអេដស៍ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ដែលត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ប្រកាសឱ្យប្រើតាម ព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ។ នៅក្នុងជំពូកទី៧ ស្តីពីការរក្សាភាពសម្ងាត់ វាក្យខណ្ឌទីមួយនៃមាត្រា៣៣ នៃច្បាប់នេះចែងថា អ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ត្រូវទទួលបានការរក្សាភាពសម្ងាត់ ។ ការចេញផ្សាយរូបថតច្បាស់ៗ សម្លេង ទីកន្លែងរស់នៅពិតប្រាកដ និង ស្ថានភាពឯទៀតនៃអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ជាការទម្លាយភាពសម្ងាត់នៃអ្នកមានជំងឺអេដស៍ ដែលជាការរំលោភបំពានលើមាត្រា៣៣នៃច្បាប់ខាងលើ ។ ការរំលោភបំពាននេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០០០ (ប្រាំម៉ឺន) រៀល ដល់ ២០០០០០ (ម្ភៃម៉ឺន) រៀល និង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ៦ខែ ដូចមានចែងក្នុងមាត្រា៥១ នៃច្បាប់ដដែលខាងលើ ។

អាស្រ័យដូចបានជម្រាបខាងលើ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍សូមអំពាវនាវ និងណែនាំដល់បណ្តាញព័ត៌មានទាំងអស់ ឱ្យធ្វើការប្រុងប្រយ័ត្ន ចេះរក្សាភាពសម្ងាត់ ចេះលាក់បាំងអត្តសញ្ញាណរបស់អ្នកផ្ទុកមេរោគអេដស៍ ដូចជាមិនបង្ហាញរូបថតច្បាស់ៗ សម្លេង និង ទីកន្លែងរស់នៅពិតប្រាកដរបស់អ្នកទាំងនោះជាដើម មុននឹងចេញផ្សាយជាសាធារណៈ ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានជំនឿថាបណ្តាញព័ត៌មានទាំងអស់ នឹងលើកតម្កើង ក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួនឱ្យខ្ពស់ ដើម្បីកុំឱ្យការប្រើប្រាស់សេរីភាពសារព័ត៌មាន ក្លាយជាការរំលោភបំពានលើសិទ្ធិរបស់អ្នកផ្ទុកមេរោគអេដស៍ ក៏ដូចជាការរំលោភលើច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤

អាសយដ្ឋាន : អគារលេខ១៦ ផ្លូវលេខ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់II ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥)២៣ ៨៨៥ ១២៩